## តើអ្នកបានដឹងទេថា ការបញ្ចុះតំលៃលើសេវាកម្ម ទូរស័ព្ទ គឺអាចមានជូនដល់បណ្តាអតិថិជន ដែលមានប្រាក់ចំណូលទាបដែរឬទេ?

*California Lifeline* ផ្តល់ជូនការបញ្ចុះតំលៃលើសេវាកម្មទូរស័ព្ទជូនដល់បណ្តាអតិថិជនដែលមានលក្ខណៈសម្បត្តិ។ លោកអ្នកប្រហែលជាអាចទទួលបាននូវការបញ្ចុះតំលៃទាំងសេវាកម្មទូរស័ព្ទតាមផ្ទះ ឬ សេវាកម្មមិនមានខ្សែ ប៉ុន្តែប្រហែលជាមិនអាចទទួលបាននូវការបញ្ចុះតំលៃសម្រាប់សេវាកម្មទាំងពីរនៅក្នុងពេលតែមួយបានទេ។



ដើម្បីយល់ដឹងបន្ថែមអំពី

**California Lifeline:**

សូមហៅទូរស័ព្ទមកកាន់ក្រុមហ៊ុនទូរស័ព្ទប្រចាំតំបន់របស់លោកអ្នក ហើយសាកសួរអំពី California Lifeline ឬសូមទៅកាន់ www.californialifeline.com

California Public Utilities Commission

**Telecommunications Education and Assistance in Multiple-Languages (TEAM) Program**

www.cpuc.ca.gov/team-and-changes

cabteamandchanges@cpuc.ca.gov

If you are not able to resolve your dispute with your service provider, call the Consumer Affairs Branch (800) 649-7570

# គន្លឹះសម្រាប់ការជ្រើសរើស សេវាកម្ម ទូរស័ព្ទចល័ត

គណៈកម្មការ សេវាកម្មសាធារណៈ ប្រចាំរដ្ឋកាលីហ្វ័រញ៉ា





# គន្លឹះទាំង 8

## 1 ជ្រើសរើសផែនការដែលត្រឹមត្រូវសម្រាប់លោកអ្នក

ផែនការទាំងនេះអាចរួមបញ្ចូលទាំងការផ្សំសេវាកម្មណាមួយនៃសេវាកម្មជាសំលេង ការវាយសារ និងទិន្នន័យ ។ ក្រុមហ៊ុនផ្តល់ជូននូវចំនួនមានកំណត់ ឬមិនកំណត់នូវនាទីនៃពេលវេលាសារជាសំលេង សារជាអត្ថបទ និងទិន្នន័យ ដើម្បីប្រើប្រាស់នៅពេលវេលាជាក់លាក់ ឬពេលវេលាណាមួយ ។

សូមសាកសួរអំពី តម្លៃផែនការនិមួយៗ ។

## 3 ជម្រើសកិច្ចសន្យារយៈពេលវែង

សូមសាកសួរអំពីផែនការប្រចាំខែ ឬ "បង់ប្រាក់នៅពេលអ្នកប្រើប្រាស់" ។ សូមសាកសួរអំពីចំនួននាទីដែលអ្នកចាប់ផ្តើមជាមួយ និងរបៀប និងពេលវេលាត្រូវទិញចំនួននាទីបន្ថែម ។

## 4 យល់ដឹងអំពី "ប្រព័ន្ធ Roaming"

កំរៃសម្រាប់ប្រព័ន្ធ Roaming អាចអនុវត្តនៅពេលដែលលោកអ្នកកំពុងប្រើប្រាស់ទូរស័ព្ទរបស់លោកអ្នកនៅលើបណ្តាញទូរស័ព្ទរបស់ក្រុមហ៊ុនផ្សេងទៀត ។ ត្រូវដឹងថាកំរៃសម្រាប់ប្រព័ន្ធ roaming អាចមានតម្លៃថ្លៃ ។ សូមសាកសួរថាតើកំរៃសម្រាប់ប្រព័ន្ធ roaming នឹងត្រូវបានអនុវត្តន៍ឬទេ របៀបដែលអ្នកដឹងថាតើអ្នកកំពុងប្រើប្រាស់ប្រព័ន្ធ roaming និងថាតើសេវាកម្មទាំងអស់របស់អ្នកនឹងអាចមានប្រើប្រាស់នៅពេលកំពុងប្រើប្រាស់ប្រព័ន្ធ roaming ឬទេ។

## 5 ឧបករណ៏សម្រាប់ទូរស័ព្ទដៃ

សូមសាកសួរអំពីតម្លៃនៃឧបករណ៏មួយ និងប្រសិនបើតម្លៃខុសៗគ្នា ថាតើមាន ឬមិនមានកិច្ចសន្យា ។ ហើយក៏សូមសាកសួរផងដែរថាតើឧបករណ៏នេះតម្រូវសម្រាប់សេវាកម្មជាក់លាក់ឬទេ ។

## 6 ការទាញយកលក្ខណៈពិសេសៗបន្ថែម

សូមសាកសួរអំពីកំរៃដែលដាក់អនុវត្តន៏សំរាប់ការទាញយកបទភ្លេង ល្បែង កម្មវិធី ឬ "Apps" និងព័ត៌មានផ្សេងៗ ប្រសិនបើពួកវាមិនត្រូវបានរួមបញ្ចូលនៅក្នុងផែនការរបស់លោកអ្នក ។ លោកអ្នកអាចទទួលខុសត្រូវចំពោះ "Apps" ណាមួយដែលក្រុមគ្រួសារ ឬមិត្តភ័ក្ររបស់លោកអ្នកទាញយកនៅពេលកំពុង ប្រើប្រាស់ទូរស័ព្ទរបស់លោកអ្នក ។ អ្នកប្រហែលជាចង់រឱ្យឃើញ ថាតើអ្នកអាចបិទការទាញយកនៅលើទូរស័ព្ទរបស់លោកអ្នក ។

## 7 ការផ្លាស់ប្តូរក្រុមហ៊ុន

ប្រសិនបើលោកអ្នកផ្លាស់ប្តូរក្រុមហ៊ុនទូរស័ព្ទ លោកអ្នកអាចរក្សាលេខទូរស័ព្ទរបស់លោកអ្នក ។ វាជាការប្រសើរបំផុត ដែលត្រូវប្តូរក្រោយពេលដែលកិច្ចសន្យារបស់អ្នកផុតកំណត់ បើមិនដូច្នេះទេអ្នកត្រូវបង់កំរៃសម្រាប់ការបញ្ចប់មុនពេលកំណត់ ។ លោកអ្នកក៏អាចត្រូវទិញទូរស័ព្ទចល័តថ្មីគ្រឿងផងដែរ ដោយសារតែទូរស័ព្ទចល័តជាច្រើន ដំណើរការតែជាមួយបណ្តាញរបស់ក្រុមហ៊ុនជាក់លាក់តែប៉ុណ្ណោះ ។







## 2 រយៈពេលនៃការសាកល្បងរបស់លោកអ្នក

សូមស្វែងរករយៈពេលដែលលោកអ្នកត្រូវសាកល្បងលក្ខណៈពិសេសៗ សេវាកម្ម និងតំបន់គ្របដណ្តប់របស់ទូរស័ព្ទរបស់លោកអ្នក ដោយមិនមានការបង់ប្រាក់ និងកំរៃនៃការបញ្ចប់មុនពេលកំណត់ ប្រសិនបើលោកអ្នកសម្រេចឈប់ប្រើប្រាស់សេវាកម្ម ។

## 8 ត្រូវយល់ដឹងអំពីកំរៃរបស់លោកអ្នក

ស្នើសុំមើលវិក្ក័យប័ត្រគំរូមួយដែលមានការប៉ាន់ស្មាននូវអ្វីដែលអ្នកនឹងធ្វើការបង់ប្រាក់ជារៀងរាល់ខែ ។ អ្នកគួរដឹងអំពីកំរៃ សម្រាប់ការដំណើរការឡើងវិញ ពន្ធ និងការគិតកំរៃបន្ថែម ។